**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ

លេខ : ០០៥/២៤ ក.ប/ស.ជ.ណ.អ.ក.ស

# សេចក្តីជូនដំណឹង
## ស្តីពី
## ការជ្រើសរើសសិស្ស-និស្សិត អាហារូបករណ៍ថ្នាក់សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ទៅសិក្សានៅ Shenzhen Polytechnic University សាធារណរដ្ឋប្រជាមានិតចិន

**យោង៖** លិខិតចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២៤ របស់ CIIC International Education Technology (Beijing) Co., Ltd. (CIICIE) នៃសាធារណរដ្ឋប្រជាមានិតចិន។

ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សូមជម្រាបជូនដំណឹងដល់ **សិស្ស-និស្សិត និងសាធារណជនទាំងអស់** ជ្រាបថា តាមរយៈកិច្ចសហការរវាងក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ និង CIIC International Education Technology (Beijing) Co., Ltd. (CIICIE) នៃសាធារណរដ្ឋប្រជាមានិតចិន ក្នុងឆ្នាំសិក្សា ២០២៤-២០២៥ នេះ CIICIE បានផ្តល់អាហារូបករណ៍កម្រិតសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស លើមុខជំនាញ **Animation Production Technology** សម្រាប់សិស្ស-និស្សិតកម្ពុជាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ (ចំនួន ៣០រូប) សិក្សានៅ **Shenzhen Polytechnic University** រយៈពេល៣ឆ្នាំ ដោយភាគីចិនទទួលរ៉ាប់រង លើថ្លៃសិក្សា និងការស្នាក់នៅ រីឯការហូបចុក និងការចំណាយលើថ្លៃសំបុត្រយន្តហោះជាបន្ទុករបស់សាមីខ្លួន។

**១-លក្ខខណ្ឌនៃការជ្រើសរើស**

បេក្ខជនទាំងពីរភេទត្រូវ៖

- មានអាយុចាប់ពី១៨ឆ្នាំឡើង
- ជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (អាទិភាពសម្រាប់សិស្សដែលមាននិទ្ទេសល្អ)
- មានសុខភាពល្អ និងឧស្សាហ៍ព្យាយាមក្នុងការសិក្សា។

**២-ឯកសារដែលត្រូវបំពេញ និងជូនភ្ជាប់**

- ពាក្យស្នើសុំអាហារូបករណ៍......................................................ចំនួន០១ច្បាប់
- ព្រឹត្តប័ត្រពិន្ទុមធ្យមសិក្សាទុតិយភូមិ (ភាសាអង់គ្លេស)............................ចំនួន០១ច្បាប់
- សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (ភាសាអង់គ្លេស) ..............................ចំនួន០១ច្បាប់
- លិខិតថ្កោលទោស (ជាភាសាអង់គ្លេស)................................................ចំនួន០១ច្បាប់
- វិញ្ញាបនបត្របញ្ជាក់អំពីចំណេះដឹងផ្នែកភាសាអង់គ្លេស ............................ចំនួន០១ច្បាប់
- លិខិតឆ្លងដែនថតចម្លង ...........................................................................ចំនួន០១ច្បាប់

**៣-<u>កាលបរិច្ឆេទ និងទីកន្លែងទទួលពាក្យ</u>**

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **សាធារណជន សិស្ស-និស្សិត** ដែលមានបំណងដាក់ពាក្យសុំអាហារូបករណ៍នេះ សូមបំពេញសំណុំឯកសារផ្សេងៗ និងផ្ញើមក **ការិយាល័យទំនាក់ទំនង និងអាហារូបករណ៍ នៃនាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា** ដែលមានអាសយដ្ឋាន៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកថ្លា ខណ្ឌទួលគោក រាជធានីភ្នំពេញ ចាប់ពីថ្ងៃផ្សព្វផ្សាយដំណឹងនេះរហូតដល់ **ថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៤ ត្រឹមម៉ោង៥:០០រសៀល។**

សម្រាប់ព័ត៌មានបន្ថែម បេក្ខជនអាចទាក់ទងសួរនៅការិយាល័យទំនាក់ទំនង និងអាហារូបករណ៍ តាមរយៈអាសយដ្ឋានខាងលើ ទូរស័ព្ទលេខ: ០១២ ៨៣៩ ០៤០ ឬ Email pumsela@gmail.com។

ថ្ងៃសុក្រ ៥រោច ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

សូម SCAN ដើម្បីទាញយក
ឯកសារពាក់ព័ន្ធខាងក្រោម៖